# បដិមាព្រះពុទ្ធប្រក់នាគបញ្ជូនពីអាមេរិកមកកម្ពុជានៅឆ្នាំ២០២៤

ដូចបានផ្សាយនៅក្នុងអត្ថបទមុន វត្ថុបុរាណខ្មែរចំនួន ៧០ ដុំ ដែលជនទុច្ចរិតលួចយកចេញ និងចរាចរលក់ដូរដោយខុសច្បាប់ទៅក្រៅប្រទេស បានវិលត្រឡប់មកកម្ពុជាវិញកាលពីខែកក្កដា ឆ្នាំ២០២៤ ក្រោមកិច្ចខិតខំប្រឹងប្រែងដោយរាជរដ្ឋាភិបាលកម្ពុជាដែលមានក្រសួងវប្បធម៌និងវិចិត្រសិល្បៈជាសេនាធិការ។ ក្នុងចំណោមនោះមានបដិមាសំខាន់ៗចំនួន ៣៣ ដុំ ត្រូវបានប្រគល់មកវិញដោយគ្រួសារ Lindemann នៃសហរដ្ឋអាមេរិក។ គួរឱ្យចាប់អារម្មណ៍ ក្នុងចំណោមវត្ថុបុរាណទាំងនោះ មានបដិមាព្រះពុទ្ធប្រក់នាគចំនួន ១ អង្គ ប៉ុន្តែបដិមានេះគេមិនដឹងថាមានប្រភពដើមមកពីប្រាសាទណាមួយនៃប្រទេសកម្ពុជាទេ ហើយបច្ចុប្បន្នកំពុងដាក់តាំងបង្ហាញនៅសារមន្ទីរជាតិកម្ពុជា។ តើបដិមាព្រះពុទ្ធប្រក់នាគមួយអង្គនេះមានលក្ខណៈដូចម្តេចខ្លះ?

បដិមាព្រះពុទ្ធប្រក់នាគដែលមិនស្គាល់ប្រភព និងបានបញ្ជូនមកពីសហរដ្ឋអាមេរិកមកកាន់កម្ពុជានៅឆ្នាំ២០២៤ នេះ សាងឡើងអំពីថ្មភក់ មានកម្ពស់ ១៨០ស.ម. ទទឹង ៩,៥ស.ម. និងកម្រាស់ ៥៧ស.ម. ដែលគេអាចចាត់ថ្នាក់ចូលក្នុងសិល្បៈខ្មែររចនាបថបាយ័ន្ត (ស.វ.ទី១២ - ដើមស.វ.ទី១៣)។ បដិមាព្រះពុទ្ធប្រក់នាគនេះ អង្គុយពែនភ្នែនក្នុងកាយវិការសមាធិ ដោយយកព្រះហស្តទាំងពីរដាក់ត្រួតលើគ្នា ព្រះនេត្របិទ ព្រះកាណ៌វែង ព្រះឱស្ឋក្រាស់ ព្រះនាសាមានខ្ពង់ និងមានព្រះកេសរួញជាដុំមូល តូចៗដោយមានឧស្ណីស(ដុំប៉ោង)នៅចំកណ្តាល ដែលជានិម្មិតរូបនៃប្រាជ្ញាដ៏លើសលប់របស់ព្រះពុទ្ធអង្គ។ បដិមានេះមានលក្ខណៈទូទៅស្រដៀងទៅនឹងបដិមាព្រះពុទ្ធប្រក់នាគមួយអង្គទៀត (កម្ពស់៣,៦០ម៉ែត្រ) ដែលរកឃើញនៅប្រាង្គកណ្តាលប្រាសាទបាយ័ន្តនៅក្នុងឆ្នាំ១៩៣៣ ដោយលោក George Trouvé ។ បន្ទាប់ពីបានឃើញបដិមានេះ លោក George Coedès (១៩៤០) សន្និដ្ឋានថា បដិមានេះជារូបតំណាងរបស់ព្រះពុទ្ធក្នុងលក្ខណៈជាស្តេចជ័យវរ្ម័នទី៧ ឬហៅម្យ៉ាងទៀតថា “**ពុទ្ធរាជា**”។ ទោះបីជាយ៉ាងណា សិលាចារឹកខ្មែរជាង ១៥០០ ផ្ទាំងមិនបានបញ្ជាក់អំពីព្រះនាមព្រះពុទ្ធអង្គនេះឡើយ។ ផ្ទុយទៅវិញ អ្នកស្រាវជ្រាវជាច្រើន សន្និដ្ឋានថាជាព្រះពុទ្ធអង្គប្រក់នាគនេះ គឺជា “**ព្រះពុទ្ធសក្យមុនី**” (ព្រះពុទ្ធគង់នៅស្ថានមនុស្ស) ដែលកំពុងការពារដោយនាគឈ្មោះ “**មុចិលិន្ទ**” ដែលជារឿងទេវកថាព្រះពុទ្ធសាសនាថេរវាទ និងជានិកាយ

អត្ថបទដោយ៖ ម៉ង់ វ៉ាលី

មួយដែលខ្មែរកំពុងគោរពប្រណិប័តន៍បច្ចុប្បន្ន។ ក្រោយមក នៅក្នុងពេលថ្មីៗនេះ លោក Peter D. Sharrock (២០២២) បានផ្តល់សេចក្តីសន្និដ្ឋានថ្មីមួយថា បដិមាព្រះពុទ្ធប្រក់នាគដែលបានកសាងឡើងនៅរវាងស.វ.ទី១២ និងទី១៣ នាសម័យអង្គរទាំងនោះ ទំនងជារូបតំណាងឱ្យ “**ព្រះអមិតាភ**” (ប្រែថា៖ “ពន្លឺគ្មានកំណត់)ដែលជាព្រះពុទ្ធមួយអង្គ (ជិននាថ) ក្នុងចំណោមព្រះធ្យានិពុទ្ធទាំងប្រាំ។ ទ្រង់ប្រចាំនៅទិសខាងលិច និងគង់នៅស្ថានសួគ៌មានឈ្មោះថា “**សុខាវតី**” នៃលទ្ធិព្រះពុទ្ធសាសនាមហាយាន ដែលស្ថានសួគ៌នេះគេជឿថាជាកន្លែងដែលពោរពេញដោយសន្តិភាព និងរីករាយបំផុតសម្រាប់អ្នកបដិបត្តិធម៌ដើម្បីសម្រេចការត្រាស់ដឹង។

មកទល់បច្ចុប្បន្ននេះ ព្រះពុទ្ធអមិតាភក្នុងទម្រង់ជាបដិមានៅក្នុងសិល្បៈខ្មែរពុំមាននរណាហ៊ានអះអាងឱ្យជាក់លាក់ឡើយ ពោល គឺមានតែចម្លាក់តូចៗឆ្លាក់នៅលើផ្នួងសក់ព្រះពោធិសត្វតែប៉ុណ្ណោះ។ ប៉ុន្តែ ការសិក្សាស្រាវជ្រាវ និងសេចក្តីសន្និដ្ឋានថ្មីរបស់លោក Peter D. Sharrock គឺយោងទៅលើភស្តុតាងសិលាចារឹក (ប្រាសាទបឹងវៀង K.872) ដែលមានកត់ត្រាព្រះនាមព្រះពុទ្ធអមិតាភ និងរៀបរាប់អំពីស្ថានសួគ៌សុខាវតី ព្រមទាំងយោងទៅលើភស្តុតាងផ្នែកប្រវត្តិសិល្បៈចំនួន ២ សំខាន់ គឺថ្មគោលព្រះពុទ្ធសាសនាដែលកំពុងរក្សាទុកនៅសារមន្ទីរហូណូលូលូ សហរដ្ឋអាមេរិក និងព្រះពុទ្ធប្រក់នាគដែលរកឃើញនៅប្រាសាទផ្ទី (តម្កល់នៅកណ្តាលអាងស្តុកទឹកប្រាសាទបឹងមាលា)។ ព្រះពុទ្ធប្រក់នាគនៅប្រាសាទផ្ទី គេដាក់តម្កល់នៅលើបង្គោលថ្មរាងប្រាំបីជ្រុងយ៉ាងខ្ពស់ឱ្យផុតពីទឹក ដែលលោកយល់ថា សសរនាគនោះហាក់ដូចជាមានទំនាក់ទំនងក្នុងនិម្មិតរូបបញ្ជាក់ឱ្យឃើញអំពីការឡើងនិងចុះរវាងស្ថានសួគ៌និងសមុទ្រ។ សសរបង្គោលនាគខ្ពស់នេះ ក៏ហាក់ដូចជាចង់បង្ហាញអំពីនិម្មិតរូបដែលព្រះពុទ្ធអង្គកំពុងគង់នៅស្ថានសួគ៌ ពោល គឺព្រះពុទ្ធអមិតាភ ហើយពុំមែនជាព្រះពុទ្ធសក្យមុនីដែលគង់នៅស្ថានមនុស្ស។ ករណីបែបនេះ យើងឃើញមាននៅក្នុងព្រះវិហារវត្តក្តីដើម ដែលព្រះពុទ្ធប្រក់នាគមួយអង្គ (យកមកពីប្រាសាទបឹងព្រៃខ្វី) គេតម្កល់នៅលើបង្គោលខ្ពស់មួយដូចគ្នា។ ម៉្លោះហើយ នាគដែលប្រក់ព្រះពុទ្ធអង្គនោះក៏អាចមិនមែនជាមុចិលិន្ទដែរ តែអាចជានិមិត្តរូបនៃការឃើតយោងដំណើរទៅកាន់ស្ថានសួគ៌ច្រើនជាង។

ទោះបីជាការសន្និដ្ឋានថ្មីថាព្រះពុទ្ធប្រក់នាគ ប្រហែលជាព្រះពុទ្ធអមិតាភនៅស្ថានសុខាវតីដូចនេះក្តី គំនិតរបស់លោក George Trouvé ដែលយល់ថាព្រះពុទ្ធប្រក់នាគរកឃើញនៅប្រាសាទបាយ័ន្តនៅក្នុងឆ្នាំ១៩៣៣ គឺជា “**ពុទ្ធរាជា**” (ការភ្ជាប់រវាងព្រះមហាក្សត្រជាមួយព្រះជិននាថ) ក៏

អត្ថបទដោយ៖ ម៉ង់ រ៉ាលី

មិនមានការបដិសេធដែរ។ ដ្បិត ភស្តុតាងសិលាចារឹកនៅចុងស.វ.ទី១២ និងដើមស.វ.ទី១៣ (សិលាចារឹកភិមានអាកាស K.485) គឺបានប្រាប់ឱ្យដឹងអំពីការកសាងរូបសំណាកព្រះមហាក្សត្រ និងព្រះរាជវង្សានុវង្សពិតប្រាកដមែន។ ការភ្ជាប់ព្រះមហាក្សត្រជាមួយព្រះពុទ្ធជិននាថនៅពេលនេះ គេយល់ថា ជារូបភាពព្រះបាទជ័យវរ្ម័នទី៧ នៅពេលទ្រង់អស់ព្រះជន្មហើយ ពោល គឺក្នុងគំនិតថាសូមឱ្យព្រះអង្គនិងព្រះញាតិវង្សបានទៅសោយសុខនៅស្ថានសុខាវតីដូចព្រះពុទ្ធអមិតាភដែរ។ ផ្ទុយពីរូបសំណាកដែលអ្នកស្រាវជ្រាវ និងអ្នកផងទូទៅស្គាល់គ្រប់គ្នាថា **“រូបតំណាងព្រះបាទជ័យវរ្ម័នទី៧”** (សព្វថ្ងៃតាំងបង្ហាញនៅសារមន្ទីរជាតិកម្ពុជា) ដែលអង្គុយពែនភ្នែនសមាធិ និងមិនមានតុបតែងសក់រួញដូចព្រះពុទ្ធនោះ ប្រហែលទំនងជារូបសំណាកតំណាងឱ្យព្រះបាទស្រីជ័យវរ្ម័នទី៧ កាលទ្រង់នៅមានព្រះជន្ម។ ម្ល៉ោះហើយ បដិមាព្រះពុទ្ធប្រក់នាគដែលទើបបញ្ជូនត្រឡប់មកពីសហរដ្ឋអាមេរិក (មិនស្គាល់ប្រភព) មកកាន់ប្រទេសកម្ពុជាក្នុងខែកក្កដា ឆ្នាំ២០២៤ ដែលយើងកំពុងលើកយកសិក្សានៅពេលនេះ ប្រហែលជារូបសំណាកតំណាងឱ្យព្រះបាទជ័យវរ្ម័នទី៧ ភ្ជាប់ជាមួយនឹងព្រះពុទ្ធអមិតាភ នៅពេលទ្រង់បានសោយទិវង្គតហើយ។

សូមបញ្ជាក់ថា នីតិវិធីនៃការទាមទារយកបដិមានេះត្រឡប់មកវិញ គឺធ្វើឡើងដោយមានកិច្ចសហការជាពិសេសរវាងរាជរដ្ឋាភិបាលកម្ពុជា ដែលមានក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ជាសេនាធិការ និងសហរដ្ឋអាមេរិក។ ក្នុងនោះ ការិយាល័យមេធាវីសហរដ្ឋអាមេរិកប្រចាំសង្កាត់ភាគខាងត្បូងនៃទីក្រុងញូវយ៉ក (SDNY) និងក្រសួងសន្តិសុខមាតុភូមិអាមេរិក បានស៊ើបអង្កេតរយៈពេល ៣ ឆ្នាំ ហើយបានចោទប្រកាន់លោក Douglas Latchford ថា បានជួញដូរវត្ថុសិល្បៈបុរាណខ្មែរដោយខុសច្បាប់។ ជាលទ្ធផលនៅខែកញ្ញា ឆ្នាំ២០២៣ គ្រួសារ Lindemann ដែលជាអ្នករក្សាទុកសមុច្ច័យវត្ថុបុរាណខ្មែរ បានស្ម័គ្រចិត្តយល់ព្រមប្រគល់វត្ថុបុរាណចំនួន ៣៣ ដុំ មកកម្ពុជាវិញ ដោយទទួលស្គាល់ថាវត្ថុបុរាណទាំងនោះ គឺកាន់កាប់ដោយខុសច្បាប់។ ក្រោយមក បដិមាព្រះអធ៌នារីស្វរ និងវត្ថុបុរាណផ្សេងទៀត បានដឹកមកដល់កម្ពុជាវិញនៅខែកក្កដា ឆ្នាំ២០២៤ និងបានធ្វើពិធីទទួលត្រឡប់មកវិញជាផ្លូវការនូវវត្ថុបុរាណខ្មែរចំនួន ៧១ ដុំ នាព្រឹកថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៤ នៅវិមានសន្តិភាព ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា។

អត្ថបទដោយ៖ ម៉ង់ វ៉ាលី

## *អត្ថបទ៖ បដិមាព្រះពុទ្ធប្រក់នាគបញ្ជូនពីអាមេរិកមកកម្ពុជានៅឆ្នាំ២០២៤*

*ជារួមមក បដិមាព្រះពុទ្ធប្រក់នាគដែលបានបញ្ជូនពីសហរដ្ឋអាមេរិកមកកាន់កម្ពុជាវិញ កាលពីខែកក្កដា ឆ្នាំ២០២៤ គឺជាភស្តុតាងបន្ថែមមួយទៀតអំពីការគោរពប្រតិបត្តិព្រះពុទ្ធសាសនា មហាយាន ឬវជ្រយាននៅក្នុងសម័យអង្គរ នាចុងស.វ.ទី១២ ដល់ស.វ.ទី១៣។ ប្រសិនបើព្រះ បដិមាព្រះពុទ្ធប្រក់នាគនេះ គឺជារូបតំណាងព្រះពុទ្ធអមិតាភដូចដែលលោក* Peter D. Sharrock *សន្និដ្ឋានមែននោះ នឹងនាំឱ្យយើងដឹងថាសាសនានៅក្នុងរជ្ជកាលព្រះបាទស្រីជ័យវរ្ម័នទី៧ គឺមាន ភាពដូចគ្នាទៅនឹងប្រទេសចិន និងជប៉ុន ព្រោះនៅស.វ.ទី១២-១៣ ជប៉ុនក៏គោរពនិកាយនេះដែរ។*

### *បញ្ជីឯកសារពិគ្រោះ*


Blanco, Camille. "Brown's Own Lindemann Family Caught in Cambodian Repatriation Scandal." *Brown Art Review*, 30 October 2023.

Xinhua. "Cambodia celebrates return of 70 looted artifacts from abroad." *Xinhua News Agency*, 22 August 2024.

Woodman, Spencer. "Lindemann family returns 33 long-sought ancient statues to Cambodia." *International Consortium of Investigative Journalists (ICIJ)*, 12 September 2023.

U.S. Attorney's Office, Southern District of New York. "U.S. Attorney Announces Return of Significant Collection of Antiquities to Cambodia." *Department of Justice Press Release*, 12 September 2023.

The Business Times. "Billionaire US collectors to return ancient artefacts to Cambodia." *The Business Times*, 13 September 2023.

**Coedès, George.** 'La destination funéraire des grands monuments khmèrs'. *Bulletin de l'École française d'Extrême Orient* 40, 1940: 315–350.

**Coedès, George.** *Inscription du Cambodge*, Tome V. 1953.

**Dowling, Nancy.** 'Honolulu Academy of Art Tenth-Century Khmer Buddhist Trinity'. *Artibus Asiae* 56(3/4), 1996: 325–341.

**Sharrock Peter, D.** 'Amitābha in Angkor?' in *Decoding Southeast Asian Art Studies,* in Honor of Piriya Krairiksh, Edited by Nicolas Revire & Pitchaya Soomjinda, River Book, Bangkok, 2022.

**Sharrock, Peter D.** *The Buddhist Pantheon of the Bàyon of Angkor: An Historical and Art Historical Reconstruction of the Bàyon Temple and Its Religious and Political Roots*. PhD dissertation, SOAS–University of London, 2006.

**Zimmer, Heinrich**. *Myths and Symbols in Indian Art and Civilization*. Edited by Joseph Campbell. Princeton: Princeton University Press, 1972.



*អត្ថបទដោយ៖ ម៉ង់ រ៉ាលី*




រូបលេខ១៖ ព្រះពុទ្ធប្រក់នាគ (មិនស្គាល់ប្រភព) បញ្ជូនមកពីអាមេរិកមកកាន់កម្ពុជា ឆ្នាំ២០២៤

អត្ថបទដោយ៖ ម៉ង់ វ៉ាលី




រូបលេខ២៖ ព្រះពុទ្ធប្រក់នាគ (មិនស្គាល់ប្រភព) បញ្ជូនមកពីអាមេរិកមកកាន់កម្ពុជា ឆ្នាំ២០២៤

អត្ថបទដោយ៖ ម៉ង់ រ៉ាលី



រូបលេខ៣៖ ព្រះពុទ្ធប្រក់នាគ (មិនស្គាល់ប្រភព) បញ្ជូនមកពីអាមេរិកមកកាន់កម្ពុជា ឆ្នាំ២០២៤

អត្ថបទដោយ៖ ម៉ង់ វ៉ាលី



*រូបលេខ៤៖ ព្រះពុទ្ធប្រក់នាគ (មិនស្គាល់ប្រភព) បញ្ជូនមកពីអាមេរិកមកកាន់កម្ពុជា ឆ្នាំ២០២៤*

អត្ថបទដោយ៖ ម៉ង់ វ៉ាលី